CITY OF LONG BEACH **PRESS RELEASE**

សេចក្តីប្រកាសព័ត៌មាន
ថ្ងៃទី 11 ខែឧសភា ឆ្នាំ 2021
ទំនាក់ទំនង ៖ មជ្ឈមណ្ឌលព័ត៌មានរួម នៃសាលាក្រុងឡុងប៊ិច, 562.570.NEWS, jic@longbeach.gov

សម្រាប់ការផ្សព្វផ្សាយភ្លាមៗ

# ឡុងប៊ិច ផ្តល់ជូន សំបុត្រជលវប្បដ្ឋាន ប៉ាស៊ីហ្វិក ជូនប្រជាពលរដ្ឋ ដែលបានចាក់វ៉ាក់សាំង COVID-19 នៅលើកដំបូង

## *សំបុត្រនេះនឹងមានផ្តល់ជូន ចាប់ពី ថ្ងៃទី 11 ដល់ ថ្ងៃទី 15 ខែឧសភា*

ឡុងប៊ិច, CA - ចាប់ពីថ្ងៃទី 11 នេះ រហូតដល់ថ្ងៃសៅរ៍ ទី 15 ខែឧសភា, ក្រសួងសុខាភិបាល និងសេវាមនុស្ស នៃសាលាក្រុងឡុងប៊ិច ផ្តល់ សំបុត្រទូទៅ ចូលទស្សនា ជលវប្បដ្ឋាន ប៉ាស៊ីហ្វិក ចំនួន ពីរសន្លឹក ជូនអ្នកដែលបានចាក់វ៉ាក់សាំង COVID-19 នៅលើកដំបូង ជាការលើកទឹកចិត្ត ឱ្យអ្នកដែលអាចចាក់វ៉ាក់សាំងបាន ទៅចាក់វ៉ាក់សាំង ។

ចៅហ្វាយក្រុង រ៉ូប៊ើត ហ្គាសៀ (Robert Garcia) «ខណៈដែលយើងបានបោះប៉ោន យ៉ាងអស្ចារ្យ ក្នុងការចាក់វ៉ាក់សាំង បាន 60% នៃប្រជាពលរដ្ឋ ឡុងប៊ិច ដែលអាចចាក់វ៉ាក់សាំងបាន និង 96% នៃជនវ័យចាស់, យើងដឹងថា ការអល់អែកមិនចង់ចាក់វ៉ាក់សាំង គឺជារឿងពិតសម្រាប់បុគ្គលមួយចំនួន ។» «យើងនឹងធ្វើគ្រប់យ៉ាង តាមដែលយើងអាចធ្វើទៅបាន ដើម្បីលើកទឹកចិត្តប្រជាពលរដ្ឋ ឱ្យមកចាក់វ៉ាក់សាំង ហើយនោះរួមទាំង ការផ្តល់គ្រឿងលើកទឹកចិត្ត ផងដែរ ។»

ចាប់ពីថ្ងៃនេះ រហូតដល់ថ្ងៃទី 15 ខែឧសភា អ្នកដែលបានចាក់វ៉ាក់សាំង Pfizer ឬ Moderna COVID-19 នៅលើកដំបូង ឬ វ៉ាក់សាំងចាក់ម្តងរបស់ Johnson & Johnson/Janssen រួច នៅកន្លែងចាក់វ៉ាក់សាំង ប្រតិបត្តិការដោយក្រុងណាមួយ នឹងទទួលបាន សំបុត្រ ចំនួន ពីរសន្លឹក សម្រាប់ចូលទស្សនា ជលវប្បដ្ឋាន ប៉ាស៊ីហ្វិក ។ កិច្ចខិតខំប្រឹងប្រែងចាក់វ៉ាក់វាំង ប្រតិបត្តិការដោយក្រុង ដែលនឹងមានផ្តល់ជូនសំបុត្រ រួមមាននៅ ៖

- មជ្ឈមណ្ឌលសន្និបាត ឡុងប៊ិច
- គ្លីនិកសហគមន៍ ចល័ត នៅឧទ្យាន អែដមៀរល ឃីត (Admiral Kidd), ម៉ាខាតធី (MacArthur), និង ហហ្វថុន (Houghton)
- យានចាក់វ៉ាក់សាំង ចល័ត សម្រាប់អ្នកចេញពីផ្ទះមិនកើត និងប្រជាពលរដ្ឋ នៅក្នុងតំបន់រងការប៉ះពាល់ខ្លាំង
- ក្រុមចាក់វ៉ាក់សាំង ចល័ត តាមសាលារៀន នៅមូលដ្ឋាន

ឃែលលី ខូឡូភី (Kelly Colopy) ប្រធាននាយដ្ឋានសុខាភិបាល និងសេវាមនុស្ស ឡុងប៊ិច បានប្រាប់ថា «តម្រូវការចាក់វ៉ាក់សាំង COVID-19 បានថមថយចុះ នៅទូទាំងរដ្ឋកាលីហ្វ័រញ៉ា និងសហរដ្ឋអាមេរិក ក្នុងរយៈពេលប៉ុន្មានសប្តាហ៍ថ្មីៗនេះ រួមទាំង ឡុងប៊ិចផងដែរ» «ខណៈឡុងប៊ិច នៅបន្តជា កម្លាំងនាំមុខមួយ ក្នុងប្រតិបត្តិការចាក់វ៉ាក់សាំង, បានចាក់វ៉ាក់សាំង ជូនប្រជាពលរដ្ឋ ជាង 300,000 នាក់

នៅទូទាំងទីក្រុង, យើងខ្ញុំប្តេជ្ញាចិត្ត ធ្វើការស្វែងរក ដំណោះស្រាយ ប្រកបដោយនវានុវត្តន៍ ដើម្បីបង្កើនចំនួនប្រជាពលរដ្ឋមកចាក់វ៉ាក់សាំង ។»

សាលាក្រុង នៅបន្តស្វែងរក គ្រឿងលើកទឹកចិត្ត និងយុទ្ធសាស្រ្តផ្សេងៗ ទៀត ដើម្បីលើកទឹកចិត្ត ប្រជាពលរដ្ឋដែលអាចចាក់វ៉ាក់សាំងបានទាំងអស់ ឱ្យការពារខ្លួនពួកគេ និងមនុស្សជាទីស្រឡាញ់ របស់ពួកគេ ពី COVID-19 ។

អ្នកដែលអាចចាក់វ៉ាក់សាំងបាន អាចមកចាក់វ៉ាក់សាំង ដោយមិនបាច់ណាត់ជួប ទុកជាមុន ចាប់ពីម៉ោង 11 ព្រឹក ដល់ម៉ោង 5 ល្ងាចបាន ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ និង ចាប់ពីម៉ោង 10 ព្រឹក ដល់ម៉ោង 3 រសៀល នៅថ្ងៃសៅរ៍ សម្រាប់ទាំង ជម្រើសបើកយានជំនិះ ចូលមកចាក់ និង ជម្រើសដើរចូលមកចាក់ នៅមជ្ឈមណ្ឌលសន្និសិទ ឡុងប៊ិច ។ អ្នកដែលមានចំណាប់អារម្មណ៍ ចង់ធ្វើការណាត់ជួប នៅកាលបរិច្ឆេទណាមួយ នៅតែអាចធ្វើទៅបាន ដោយចូលទៅ ច្រកវ៉ាក់របស់រដ្ឋ គឺ [MyTurn.ca.gov](MyTurn.ca.gov) ឬដោយទូរសព្ទទៅបណ្តាញលេខទាន់ហេតុការណ៍របស់ CA COVID-19 គឺ 833.422.4255 ។

គិតត្រឹមថ្ងៃទី 10 ខែឧសភា មានករណី COVID-19 ចំនួន 53,107 នៅឡុងប៊ិច ហើយប្រជាពលរដ្ឋ ចំនួន 932 នាក់ បានបាត់បង់ជីវិត ដោយសារវីរុសនេះ ។ វ៉ាក់សាំង ជាង 311,000 ដូស ត្រូវបានចាក់ជូនប្រជាពលរដ្ឋ ដែលរួមមាន 180,000 ដូស ជាការចាក់ លើកទីមួយ និង ជិត 132,000 ជាការចាក់លើកទីពីរ ។ វ៉ាក់សាំងទាំងអស់ត្រូវបានចាក់ជូន ដោយឥតគិតថ្លៃ ហើយមានផ្តល់ឱ្យ ដោយផ្ទាល់ពីរដ្ឋាភិបាលសហព័ន្ធ ។

សម្រាប់ព័ត៍មានចុងក្រោយបំផុត អំពី COVID-19 ដែលមានសេចក្តីលំអិត អំពីសកម្មភាពទាំងអស់ របស់សាលាក្រុងឡុងប៊ិច ក្នុងការរក្សាសុវត្ថិភាព របស់ប្រជាពលរដ្ឋរបស់យើង សូមចូលទៅ [long-beach.gov/COVID19](long-beach.gov/COVID19) ហើយតាម @LongBeachCity នៅលើ Facebook, Twitter និង Instagram ។

# # #